# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :........០០៣/២១..........ក.ប/ស.ណ.ន.ទ.ជិ.ម.ក

# សេចក្តីណែនាំ

## ស្តីពី

## វគ្គបណ្តុះបណ្តាលជំនាញទន់ និងសុវត្ថិភាពនិងសុខភាពការងារសម្រាប់កម្មការិនីសម្រាលកូន ដែលធ្លាប់ព្យួរកិច្ចសន្យាការងារក្នុងអំឡុងខែមីនា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២១ ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

យោងតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយផលប៉ះពាល់លើវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ជំងឺកូវីដ-១៩ និងកិច្ចព្រមព្រៀងអនុវត្តគម្រោងរវាងទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) និងអង្គការអន្តរជាតិខាងការងារ (ILO) ស្តីពី "វគ្គបណ្តុះបណ្តាលជំនាញទន់ និងសុវត្ថិភាពនិងសុខភាពការងារសម្រាប់កម្មការិនីសម្រាលកូន ដែលធ្លាប់ព្យួរកិច្ចសន្យាការងារក្នុងអំឡុងខែមីនា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២១" ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ប្រធានអង្គភាពក្រោមឱវាទក្រសួង ម្ចាស់ ឬនាយករោងចក្រ និងកម្មការិនីផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដូចខាងក្រោម៖

**សម្រាប់ម្ចាស់ ឬនាយករោងចក្រ ត្រូវ៖**

- សហការ និងជួយជូនដំណឹងដល់កម្មការិនីដែលបានសម្រាលកូន ហើយធ្លាប់ព្យួរកិច្ចសន្យាការងារក្នុងអំឡុងខែមីនា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២១ ឱ្យចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភចំនួន ៩០ ដុល្លារអាមេរិក
- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់កម្មការិនីឱ្យបានចុះឈ្មោះជាមួយមន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដើម្បីត្រៀមចូលរៀន
- ផ្តល់ទីកន្លែង និងពេលវេលា សម្រាប់មន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ ជួបផ្ទាល់ជាមួយកម្មការិនីដើម្បីផ្សព្វផ្សាយអំពីវគ្គបណ្តុះបណ្តាល និងផ្ទៀងផ្ទាត់អត្តសញ្ញាណកម្មការិនីដែលមានក្នុងបញ្ជីឈ្មោះឱ្យបានត្រឹមត្រូវតាម លក្ខខណ្ឌនៃគម្រោង ដូចជា ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខទូរស័ព្ទ និងការផ្តិតស្នាមមេដៃ។

**សម្រាប់កម្មការិនី ត្រូវ៖**

- ជាកម្មការិនីសម្រាលកូនដែលធ្លាប់ព្យួរកិច្ចសន្យាការងារក្នុងអំឡុងខែមីនា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២១ នៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ព្រមទាំងត្រូវមានប័ណ្ណសមាជិក ប.ស.ស. និងសៀវភៅការងារជនកម្ពុជា
- ផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទផ្ទាល់ខ្លួនដែលអាចទាក់ទងបានដល់ម្ចាស់ ឬនាយករោងចក្រ ដើម្បីចងក្រងជាបញ្ជីផ្តល់ជូនក្រសួង យកទៅរៀបចំនីតិវិធីបើកផ្តល់ប្រាក់ឧបត្ថម្ភតាមរយៈធនាគារវីង (ខេមបូឌា) ម.ក ទៅកម្មករនិយោជិត។ ប្រសិនបើគ្មានលេខទូរស័ព្ទផ្ទាល់ខ្លួនត្រូវផ្តល់លេខទូរស័ព្ទជារបស់ប្តី កូន ឪពុក ម្តាយ បងប្អូនបង្កើត និងមិនត្រូវផ្លាស់ប្តូរលេខទូរស័ព្ទជាដាច់ខាត
- ចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់តាមអនឡាញ ដោយត្រូវទាញយកកម្មវិធីបណ្តុះបណ្តាលនៅលើទូរស័ព្ទដៃ ដែលមានឈ្មោះ "NEA Soft Skill" និងបំពេញព័ត៌មានផ្ទាល់ខ្លួនតាមការណែនាំឱ្យបានត្រឹមត្រូវ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤ ៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- ចូលមើលមេរៀនដែលថតជាវីដេអូចំនួន៦ ក្នុងកម្មវិធី "NEA Soft Skill" ឱ្យចប់ជាស្ថាពរយ៉ាងយូរត្រឹមថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ទើបអាចបញ្ជាក់ថា កម្មការិនីបានបញ្ចប់វគ្គបណ្តុះបណ្តាលដោយជោគជ័យ ហើយគ្រប់លក្ខខណ្ឌអាចទទួលបានប្រាក់ឧបត្ថម្ភ
- អាចទាញយកឯកសារមេរៀនបណ្តុះបណ្តាលពីក្នុងកម្មវិធីបណ្តុះបណ្តាល "NEA Soft Skill" ដើម្បីរក្សាទុកមើល ឬរៀនបន្ថែមពេលក្រោយ
- បញ្ជាក់វត្តមានចូលរៀនវគ្គបណ្តុះបណ្តាល ដោយត្រូវពិនិត្យលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទផ្ទាល់ខ្លួនដែលមានក្នុងតារាងបញ្ជី ឱ្យបានត្រឹមត្រូវ មុននឹងផ្តិតស្នាមមេដៃទទួលស្គាល់
- ចូលរៀនឱ្យទៀងទាត់ទៅតាមកម្មវិធីបណ្តុះបណ្តាល និងពេលវេលាដែលបានកំណត់
- រង់ចាំទទួលសារតាមទូរស័ព្ទពីធនាគារ វីង (ខេមបូឌា) ម.ក ដែលជូនដំណឹងអំពីចំនួនទឹកប្រាក់ដែលត្រូវទទួលបាន និងពេលវេលាក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភ។ ក្រោយពេលទទួលបានសារជូនដំណឹងតាមទូរស័ព្ទ សូមបងប្អូនយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះ ទៅភ្នាក់ងារវីងណាមួយដែលនៅជិតផ្ទះបងប្អូនបំផុត ដើម្បីបើកប្រាក់ឧបត្ថម្ភ។ ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលថវិកានោះជូនគម្រោងវិញ ប្រសិនជាបងប្អូនណាម្នាក់ខកខានទៅបើកប្រាក់ឧបត្ថម្ភនោះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីធនាគារ វីង (ខេមបូឌា) ម.ក បានផ្ញើសារតាមទូរស័ព្ទជូនកម្មការិនីរួច។

**សម្រាប់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវ៖**

- រៀបចំក្រុមការងារចុះផ្ទាល់ដល់រោងចក្រដើម្បីផ្សព្វផ្សាយ និងពន្យល់ពីនីតិវិធីនៃការចុះឈ្មោះចូលរៀន ចែកឯកសារមេរៀន និងផ្ទៀងផ្ទាត់អត្តសញ្ញាណកម្មការិនីដែលមានក្នុងបញ្ជីឈ្មោះដែលត្រូវតាមលក្ខខណ្ឌគម្រោង ដូចជា ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខទូរស័ព្ទ និងការផ្តិតស្នាមមេដៃ ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភ
- សម្របសម្រួលជាមួយរោងចក្រដើម្បីផ្តល់ព័ត៌មានអំពីគម្រោង និងកិច្ចសហការផ្សេងៗក្នុងការរៀបចំដំណើរការការងារខាងលើ
- ជូនដំណឹងដល់កម្មការិនីអំពីកាលវិភាគ និងកម្មវិធីបណ្តុះបណ្តាល
- រៀបចំ និងគ្រប់គ្រងបញ្ជីរបស់កម្មការិនីដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងរៀបចំរបាយការណ៍
- សហការជិតស្និទ្ធជាមួយ ប.ស.ស. និងនាយកដ្ឋានអធិការកិច្ចការងារ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះកម្មការិនី និងរោងចក្រ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ៖ ០១២ ៩០៦ ៦៦៤, ០១២ ២៣៦ ៦៦៤ និង ០៣១ ៦៣៤ ៧៦៦៦ ឬតាមរយៈក្រុមតេឡេក្រាមសម្រាប់កម្មករនិយោជិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ https://t.me/KhmerWorkerChat។

ទទួលបានសេចក្តីណែនាំនេះ ប្រធានអង្គភាពក្រោមឱវាទក្រសួង ម្ចាស់ ឬនាយករោងចក្រ និងកម្មការិនីផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១១កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**

- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ